**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ** **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ១៧២៩ ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** **រដ្ឋមន្ត្រី**

**ក្រសួងមហាផ្ទៃ** **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៥/នស/រកម/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញលិខិតលេខ ១២៣ សជណ.អរ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ស ម្រេ ច

**ប្រការ១ -** ប្រកាសនេះមានគោលដៅដាក់បញ្ញត្តិ និងល័ក្ខខ័ណ្ឌគតិយុត្តលើការងារអធិការកិច្ចហត្ថពលកម្មបរទេស ចំពោះម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២÷** មានតែក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសតែមួយប៉ុណ្ណោះ ដែលមានភារកិច្ចធ្វើអធិការកិច្ចហត្ថពលកម្មបរទេសតាមបណ្តាសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់លិខិតបង្គាប់ការរួមចេញ ដោយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានការងារ ដោយមានជូនដំណឹងជាមុន ឬមិនជូនដំណឹងក្នុងករណីចាំបាច់ណាមួយ។

**ប្រការ៣÷** ក្នុងពេលក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសចុះត្រួតពិនិត្យ ម្ចាស់ ឬនាយក សហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវសហការជាមួយក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសក្នុងការបង្ហាញឯកសារចាំបាច់នានា ដូចខាងក្រោម៖

១-លក្ខន្តិកៈក្រុមហ៊ុន/សហគ្រាសគ្រឹះស្ថាន ( ច្បាប់ដើម ) មួយច្បាប់
២-វិញ្ញាបនបត្រចុះបញ្ជិកាចេញដោយក្រសួងពាណិជ្ជកម្មឬលិខិតមានតម្លៃស្មើ មួយច្បាប់
៣-សេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក ( ច្បាប់ដើម ) មួយច្បាប់
៤-សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចេញ-ចូល(ច្បាប់ដើម) គ្រប់ចំនួន
៥-លិខិតអនុញ្ញាតឲ្យប្រើប្រាស់ហត្ថពលកម្មបរទេស (កូតា) ( ច្បាប់ដើម ) មួយច្បាប់
៦-កិច្ចសន្យាការងាររបស់ជនបរទេសជាភាសាខ្មែរដែលបានចុះបញ្ជិកាដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត(ច្បាប់ដើម) គ្រប់ជនបរទេស
៧-លិខិតឆ្លងដែនរបស់ជនបរទេស(ច្បាប់ដើម និងថតចម្លង) និងរូបថត៤X៦ ចំនួន២សន្លឹក គ្រប់ជនបរទេស
៨-ទិដ្ឋាការចូល និងទិដ្ឋាការពន្យារចុងក្រោយដែលអនុញ្ញាតឲ្យធ្វើការងាររបស់ជនបរទេស (ច្បាប់ដើម និងថតចម្លង) គ្រប់ជនបរទេស
៩-ប័ណ្ណ និងសៀវភៅការងាររបស់ជនបរទេស (ច្បាប់ដើម និងថតចម្លង) គ្រប់ជនបរទេស
១០-សៀវភៅច្បាប់ស្តីពីការងារ និងសៀវភៅច្បាប់ស្តីពីអន្តោប្រវេសន៍ មួយច្បាប់

**ប្រការ៤÷** ជនបរទេសទាំងឡាយណាដែលប្រកបអាជីវកម្មខ្នាតតូច អាជីវកម្មរណប អាជីវកម្មពុំមាននាមករណ៍ អាជីវកម្មចល័ត អាជីវកម្មពេលរាត្រី អាជីវកម្មលើផ្ទៃទឹក ឬអាជីវកម្មផ្សេងៗទៀត ត្រូវមានលិខិតអនុញ្ញាតឲ្យប្រកបអាជីវកម្មដែលចេញឲ្យដោយស្ថាប័នមានសមត្ថកិច្ច ដើម្បីបំពេញបែបបទធ្វើប័ណ្ណការងារ និងសៀវភៅការងារ។

**ប្រការ៥÷** ការទទួលយកជនបរទេសឲ្យធ្វើការងារ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពឲ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។ គ្មានជនបរទេសណាម្នាក់អាចប្រកបមុខរបរណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានប័ណ្ណ និងសៀវភៅការងារ ដែលចេញឲ្យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៦÷** ក្នុងករណីម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តណាមួយ ដែលទទួលយកពលករបរទេសឲ្យធ្វើការងារ ឬពលករបរទេសដែលធ្វើការ ឬប្រកបមុខរបរណាមួយដោយគ្មានប័ណ្ណ និងសៀវភៅការងារ ត្រូវធ្វើការពិន័យជាប្រាក់ និងផ្តន្ទាទោសតាមទោសប្បញ្ញត្តិជំពូកទី១៦នៃច្បាប់

ស្តីពីការងារ និងផ្តន្ទាទោសតាមទោសប្បញ្ញត្តិជំពូកទី៥ និងការបណ្តេញចេញជំពូកទី៦នៃច្បាប់ស្តីពីអន្តោប្រវេសន៍។

**ប្រការ៧ ÷** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានការងារ រាយការណ៍សុំការដឹកនាំពីតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីចុះត្រួតពិនិត្យហត្ថពលកម្មបរទេសតាមបណ្តា សហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ករណីសង្ស័យថាមានការលាក់បំពួនប្រើប្រាស់ហត្ថពលកម្មបរទេសដោយខុសច្បាប់។

**ប្រការ៨ ÷** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានការងារ រាយការណ៍សុំការដឹកនាំពីតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីចុះត្រួតពិនិត្យហត្ថពលកម្មបរទេសតាមបណ្តាអាជីវកម្មពេលរាត្រី។

**ប្រការ៩ ÷** ពលករបរទេសរស់នៅតំបន់ព្រំដែន ដែលចូលមកប្រទេសកម្ពុជាក្នុងគោលបំណងប្រកបមុខរបរណាមួយដែលចូលព្រឹក-ចេញល្ងាច ឬស្នាក់នៅរយៈពេលខ្លី ត្រូវបំពេញបែបបទតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬអនុវត្តតាមកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសកម្ពុជា ត្រូវមានប័ណ្ណនិងសៀវភៅការងារ ។

**ប្រការ១០ ÷** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តណាមួយ ដែលគោរព និងអនុវត្តបានត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារ ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងផ្តល់ជូននូវលិខិត ឬប័ណ្ណសរសើរដើម្បីលើកទឹកចិត្ត។

**ប្រការ១១ ÷** ប្រកាសរួមលេខ២៧០៣ ប្រក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ ÷** អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គស្នងការនគរបាលជាតិ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងមហាផ្ទៃ និងក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋបាលរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសរួមនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៤ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

<u>កន្លែងទទួល</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១២
- ឯកសារ-កាលប្បវត្តិ